Matching Fund * Historic Preservation
NEIGHBORHOODS
P-Patch * Neighborhood Service Centers

# ក្រសួងមូលដ្ឋាននៃក្រុង SEATTLE

ក្រសួងមូលដ្ឋាន (DoN) នៃក្រុង Seattle ផ្តល់នូវធនធាននិងឱកាសនានាសំរាប់និវេសកជននៃក្រុង Seattle ដើម្បីកសាងសហគមន៍ដ៏ឲ្យរឹងមាំ និងធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃជីវិតរស់នៅរបស់សហគមន៍។ ជាមួយសហគមន៍លើសពី 180 នៅក្នុងទីក្រុង, ក្រសួងដើរតួក្នុងមុខតំណែងយ៉ាងសំខាន់ក្នុងការជួយអ្នកមូលដ្ឋានដើម្បីអភិវឌ្ឍន៍នូវសុភនិច្ឆ័យនៃទីកន្លែង និងកសាងចំណងដ៏រឹងមាំជាមួយសហគមន៍ និងរដ្ឋាភិបាលក្នុងតំបន់។

DoN *គឺ... តភ្ជាប់ទៅប្រជាជន, សហគមន៍, និងរដ្ឋាភិបាល។*

## តភ្ជាប់ទៅប្រជាជន

កម្មវិធីប្រាក់ជំនួយស៊ីនឹងមូលដ្ឋានផ្តល់ប្រាក់ជំនួយទៅឲ្យក្រុមនានានៅក្នុងតំបន់សំរាប់លំដាប់ទូទៅនៃគំរោងការផ្តើមធ្វើឲ្យចំរើននៅក្នុងមូលដ្ឋាន, ការចាត់ចែងឬការធ្វើគំរោងការ។ និវេសកជនដែលទទួលកម្មវិធីប្រាក់ជំនួយស៊ីនឹងមូលដ្ឋាន ទទួលជំនួយស៊ីនឹងការធ្វើអំណោយជាប្រាក់, ការស្ម័គ្រចិត្ត, និង/ឬធ្វើអំណោយរបស់របរនិងសេវានានារបស់ខ្លួនគេផ្ទាល់។

កម្មវិធីសួនបន្លែសហគមន៍ P-Patch គាំទ្រនិងធ្វើឲ្យសហគមន៍មានបាន ដោយយោលលើមូលដ្ឋានកសិកម្មប្រើជីធម្មជាតិនៃទីក្រុង និងឱកាសនៃការដាំបន្លែផ្សេងៗទៀត ដែលជាវប្បធម៌និងសមស្របតាមមូលដ្ឋាន។ នេះជាកម្មវិធីសួនបន្លែសហគមន៍ដ៏ធំទូលាយក្នុងទីក្រុងនៅក្នុងប្រទេស ដោយចាត់ចែងប្រហែល 70 សួនបន្លែ ដែលផ្គត់ផ្គង់ក្រុមគ្រួសារចំនួន 2000 គ្រួរ។ ជាមួយនឹងសួនបន្លែសហគមន៍, នោះវិស័យកម្មវិធីនៃសួនបន្លែយុវជន, ផ្សារសំរាប់សួនបន្លែ, និងនយោបាយម្ហូបអាហារ គបរើដល់គ្រប់ពលរដ្ឋនៃក្រុង Seattle ដែលជាការយកចិត្តទុកដាក់ធ្ងន់ដល់ពលរដ្ឋដែលមានប្រាក់ចំណូលតិចនិងជនអន្តោប្រវេសន៍ និងយុវជន។

## តភ្ជាប់ទៅសហគមន៍

អ្នកសម្របសម្រួលមណ្ឌលមូលដ្ឋាន ជួយសម្រួលនិងតភ្ជាប់មូលដ្ឋានទៅនឹងរដ្ឋាភិបាលក្រុង។ ដែលមានការិយាល័យនៅមជ្ឈមណ្ឌលសេវាមូលដ្ឋាន អ្នកសម្របសម្រួលតភ្ជាប់អង្គការសហគមន៍ជាច្រើនទូទាំងស៊កៈ នៅក្នុងរង្វង់ដ៏ធំទូលាយនៃគំរោងការមូលដ្ឋាននិងបញ្ហានានា និងធ្វើការដើម្បីចូលរួមនិងឧបត្ថម្ភគ្រប់ពលរដ្ឋនៅក្នុងមណ្ឌលរបស់ពួកគេ។

អាទិភាពនៃផែនការមូលដ្ឋាន ធ្វើការយ៉ាងជិតស្និទ្ធជាមួយមូលដ្ឋាននិងរដ្ឋាភិបាលក្រុង ដើម្បីធានាឲ្យប្រាកដថាផែនការដាំដុះនៃមូលដ្ឋាន ដែលបានអភិវឌ្ឍន៍ដោយនិវេសកជននៅដើមទសវត្សឆ្នាំ 1990 មានការជឿនលឿនលើសពីការដាំដុះក្នុងរយៈពេល 20 ឆ្នាំកន្លងមកនេះ។ ដោយថែមលើនេះ គេធ្វើការជាមួយមូលដ្ឋានជាក់លាក់ ដែលកំពុងតែផ្លាស់ប្តូរយ៉ាងខ្លាំងខ្លា, ធ្វើផែនការរបស់ពួកគេឲ្យទាន់សម័យ ដោយបង្កើតអាទិភាពជិតស្និតដល់អ្នកតំណាងផ្នែកនានានៃសហគមន៍ ដោយរួមទាំងពលរដ្ឋអន្តោប្រវេសន៍និងជនភៀសខ្លួន។

ជនអន្តោប្រវេសន៍និងជនភៀសខ្លួនដំបូង គាំទ្រនិងផ្សព្វផ្សាយសកម្មភាពនៃការចូលរួមយ៉ាងសកម្មរបស់ជនអន្តោប្រវេសន៍និងជនភៀសខ្លួននៃទីក្រុង ដើម្បីផ្តល់ឲ្យពួកគេមានសំឡេងនិងតភ្ជាប់ទៅរដ្ឋាភិបាលក្រុង។ ក្រសួងផ្តោតទៅលើការបកប្រែភាសាឲ្យមានការរីកចំរើន និងមានសេវាបកប្រែផ្ទាល់មាត់, ជំនួយបច្ចេកទេសសំរាប់ជនអន្តោប្រវេសន៍ដែលមានហាងជំនួញ, បង្កើនឲ្យមានការទទួលជំនួយមកពីក្រុង, និងបុគ្គលិកក្រុមប្រឹក្សាផ្តោតលើបញ្ហាជនអន្តោប្រវេសន៍និងជនភៀសខ្លួន។

**Seattle Department of Neighborhoods**
700 5th Avenue, Suite 1700 -- PO BOX 94649 –– Seattle, WA 98124-4649
(206)684-0464 –– TDD (206)733-9595 –– FAX (206)233-5142
www.seattle.gov/neighborhoods

## តភ្ជាប់ទៅរដ្ឋាភិបាល

មជ្ឈមណ្ឌលសេវាមូលដ្ឋានតាំងនៅក្នុងក្រុងនិមួយៗនៃមណ្ឌលទី 13 ហើយនិងបំរើជា ‘ទីស្ដីការអភិបាលក្រុងតូចៗ’ មណ្ឌលនីមួយៗមានព័ត៌មានផ្នែកសេវាក្រុង នឹងទីភ្នាក់ងារសេវាមនុស្សជាតិ, កម្មវិធីនានានឹងសកម្មភាពមូលដ្ឋាន។

សេវាបង់វិក័យប័ត្រនិងព័ត៌មានក្នុងមូលដ្ឋានៈ នៅមជ្ឈមណ្ឌលទាំងប្រាំពីរនៃមជ្ឈមណ្ឌលសេវាមូលដ្ឋាន 13, អ្នកតំណាងផ្នែកសេវាអតិថិជនជួយបំរើដល់និវេសកជនលើសពីចំនួន 225,000 នាក់ក្នុងមួយឆ្នាំៗ សំរាប់ការដាក់ពាក្យសុំធ្វើសំបុត្រឆ្លងដែន, បង់វិក័យប័ត្រទឹកភ្លើងទូរស័ព្ទ, ធ្វើច្បាប់អនុញ្ញាតចិញ្ចឹមសត្វ និងទិញសំបុត្រជិះរថយន្តក្រុង, សុំក្រដាស់ពាក្យនិងកូនសៀវភៅតូចៗដែលចាំបាច់។

កម្មវិធីរក្សាទុកប្រវត្តិសាស្ត្រ ទទួលស្គាល់និងការពារសំណង់ប្រវត្តិសាស្ត្រច្រើនជាង 400 សំណង់, ទីកន្លែង, របស់របរនិងនាវា ក៏ដូចជាមណ្ឌលប្រវត្តិសាស្ត្រទាំងប្រាំពីរទូទាំងក្រុង Seattle ផងដែរ។ កម្មវិធីនេះផ្ដល់នូវព័ត៌មានលើមូលដ្ឋាននៃការការពារប្រវត្តិសាស្ត្រក្នុងក្រុង Seattle, ដោយរួមទាំងដំណើរការនៃការចាត់តាំង និងលើផ្នែកការលើកទឹកចិត្តដល់ម្ចាស់វត្ថុ ដើម្បីជំរុញការថែរក្សានិងការជួសជុលឲ្យថ្មីឡើងវិញ។ ហើយក៏គាំទ្រដល់កិច្ចការនៃក្រុមប្រឹក្សាពលរដ្ឋជាច្រើនផងដែរ ដែលបានចូលរួមនៅក្នុងការរក្សាទុកជាប្រវត្តិសាស្ត្រនេះ។

កម្មវិធីចំបងនៃស្ថាប័ននិងសាលារៀន ផ្ដល់នូវមធ្យោបាយមួយសំរាប់មូលដ្ឋានស្ថាប័នធំៗរបស់ក្រុង Seattle (ឧ.ហ. មន្ទីរពេទ្យ, សាលារៀន, សកលវិទ្យាល័យ, មហាវិទ្យាល័យ) ដើម្បីឲ្យចូលរួមដោយផ្ទាល់នៅក្នុងផែនការអភិវឌ្ឍន៍សំរាប់ស្ថាប័នទាំងនេះ ដូច្នេះដើម្បីចំណាប់អារម្មណ៍របស់មូលដ្ឋានត្រូវបានគេយកមកពិចារណា។ កម្មវិធីត្រូវចាត់ចែងនិងបុគ្គលិកគណៈកម្មការក្រុមប្រឹក្សាពលរដ្ឋក្នុងក្រុងដែលបានចាត់តាំងសំរាប់គំរោងនិមួយៗ។

បើអ្នកត្រូវការសេវាបកប្រែភាសា, ចូរទូរស័ព្ទ (206) 684-0464, ជំរាបទៅអ្នកទទួលភ្ញៀវពីភាសាអ្នកនិយាយ ហើយអ្នកនឹងត្រូវគេតភ្ជាប់ទៅអ្នកបកប្រែ។

**Seattle Department of Neighborhoods**
700 5th Avenue, Suite 1700 -- PO BOX 94649 –– Seattle, WA 98124-4649
(206)684-0464 –– TDD (206)733-9595 –– FAX (206)233-5142
www.seattle.gov/neighborhoods